# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 18-Jan-2016, 09:52
CMS/CFO: Sann Rada

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អវតក/អជសដ

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ **សាធារណៈ/Public**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

## ការគាំទ្រសំណើរបស់លោក នួន ជា សុំឲ្យទទួលយកជាភ័ស្តុតាងនូវទូរលេខការទូតចំនួន ១១

---

ដាក់ដោយ៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

**ជំនួយការ៖**

លោកស្រី សេង សុជាតា

កញ្ញា Marie CAPOTORTO

ដាក់ជូន៖

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្តរា

ចៅក្រម Claudia FENZ

ចៅក្រម យ៉ា សុខន

| | |
|---|---|
| កញ្ញា Soumeya MEDJEBEUR | **សហព្រះរាជអាជ្ញា៖** |
| លោក Clément BOSSIS | លោកស្រី ជា លាង |
| កញ្ញា Cécile ROUBEIX | លោក Nicholas KOUMJIAN |
| កញ្ញា អ៊ុច ស្រីផាត | |
| កញ្ញា Marine BOUDJEMAA | **មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់** |
| | **មេធាវីការពារក្តីលោក នួន ជា** |

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

១. នៅថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៦ មេធាវីការពារក្ដីលោក នួន ជា បានស្នើសុំអង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") ឱ្យទទួលយកជាភស្តុតាងនូវទូរលេខការទូតចំនួន ១១ ពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២[1] អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង[2]។

២. តាមរយៈសារណានេះ មេធាវីការពារក្ដីលោក ខៀវ សំផន ("មេធាវីការពារក្ដី") គាំទ្រសំណើនេះ។

៣. មេធាវីការពារក្ដីគាំទ្រទឡ្ហីករណ៍របស់លោក នួន ជា អំពីភាពមិនអាចរកឯកសារទាំងនេះបាន នៅមុនពេលបើកការជំនុំជម្រះក្ដីលើសំណុំរឿង ០០២/០២ ភាពជាប់ពាក់ព័ន្ធ និងភាពអាចជឿទុកចិត្តបាននៃឯកសារទាំងនេះ[3]។

៤. លើសពីនេះទៅទៀត មេធាវីការពារក្ដីយល់ឃើញថា ទូរលេខការទូតទាំងនេះមានប្រយោជន៍ដល់ការស្វែងរកការពិត អនុលោមតាមវិធាន ៨៧(៤)។ ជាក់ស្ដែង ឯកសារទាំងនេះលើកឡើងជាចម្បងអំពីភាពតានតឹងរវាងកម្ពុជាប្រជាធិបតេយ្យ និងសាធារណរដ្ឋសង្គមនិយមវៀតណាម ក្នុងក្រសែភ្នែករបស់ជនជាតិអូស្ត្រាលី អាមេរិក និងថៃ ហើយផ្ដល់នូវចក្ខុវិស័យខុសពីចក្ខុវិស័យរបស់សហព្រះរាជអាជ្ញា និងដីកាដំណោះស្រាយ។

៥. ជាដំបូង ទូរលេខការទូតទាំងនេះផ្ដល់នូវព័ត៌មានសំខាន់ក្នុងការស្វែងយល់អំពីជម្លោះប្រដាប់អាវុធ។ ឯកសារទាំងនេះរៀបរាប់អំពីការវាយប្រហារផ្ទាល់រវាងកម្ពុជាប្រជាធិបតេយ្យ និងសាធារណរដ្ឋ

---

[1] សំណើរបស់ នួន ជា ស្នើសុំឱ្យទទួលយកសារទូរលេខតាមផ្លូវទូតចំនួន ១១ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០១៦ ឯកសារ E383 ("សំណើរបស់ នួន ជា E383" ជូនដំណឹងនៅថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០១៦)។

[2] "ក្នុងកំឡុងពេលសវនាការ តាមគំនិតផ្ដួចផ្ដើមរបស់អង្គជំនុំជម្រះ ឬតាមការស្នើសុំរបស់ភាគី អង្គជំនុំជម្រះអាចកោះហៅឬស្ដាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬទទួលយកនូវភស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត។ គ្រប់ភាគីដែលបានស្នើសុំត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឱ្យបានច្បាស់លាស់។ អង្គជំនុំជម្រះនឹងធ្វើសេចក្ដីសម្រេចចំពោះការស្នើសុំនោះ ផ្អែកតាមខ្លឹមសារដែលមានចែងនៅក្នុងវិធាន៨៧(៣) ខាងលើ។ ភាគីដែលស្នើសុំត្រូវតែធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថាសក្ខីកម្ម ឬភស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលការចាប់ផ្ដើមជំនុំជម្រះ"។

[3] សំណើរបស់ នួន ជា E383 កថាខណ្ឌ ៨-១៥, កថាខណ្ឌ ២៦-៣៩។

សង្គមនិយមវៀតណាម ហើយការវិភាគទៅលើឯកសារទាំងនេះនឹងអាចឱ្យអង្គជំនុំជម្រះយល់កាន់តែច្បាស់អំពីតួនាទីរបស់វៀតណាមនៅក្នុងជម្លោះជាមួយកម្ពុជា[4]។

៦. ឯកសារទាំងនេះផ្តល់នូវព័ត៌មានប្រឆាំងនឹងទស្សនៈរបស់សហព្រះរាជអាជ្ញា ដែលថា មេដឹកនាំខ្មែរក្រហមសង្ស័យអំពីអត្ថិភាពនៃការគំរាមកំហែងធ្វើរដ្ឋប្រហារ ដោយសារតែ "ហេតុការណ៍មិនត្រូវបានពន្យល់"[5]។ ជាក់ស្តែង ទូរលេខការទូតទាំងនេះផ្តល់ព័ត៌មានបច្ចុប្បន្នភាពអំពីគោលជំហររបស់វៀតណាមចំពោះរបបកម្ពុជាប្រជាធិបតេយ្យ និងអន្តរាគមន៍របស់វៀតណាមមកលើរបបនេះតាមរូបភាពផ្សេងៗ។ ជាបឋម ទូរលេខការទូតទាំងនេះលើកឡើងអំពីចេតនារបស់សាធារណរដ្ឋសង្គមនិយមវៀតណាមចង់បន្តត្រួតត្រាកម្ពុជា ក្រោយពីរំដោះវៀតណាមខាងត្បូង[6]។ ឯកសារទាំងនេះបង្ហាញអំពីការមិនទុកចិត្តលើផែនការសហព័ន្ធឥណ្ឌូចិន[7] និងលាតត្រដាងអំពីការគាំទ្រយ៉ាងសកម្មរបស់សាធារណរដ្ឋសង្គមនិយមវៀតណាមចំពោះក្រុមបំបែកខ្លួននានា ដើម្បីផ្តួលរំលំរបបកំពុងកាន់អំណាច[8]។

៧. បន្ទាប់មកទៀត ទូរលេខការទូតទាំងនេះនឹងអាចផ្តល់នូវទិដ្ឋភាពមួយខុសពីដីកាដំណោះស្រាយ ទៅលើបញ្ហាបោសសម្អាត ជាពិសេស នៅភូមិភាគបូព៌ា[9]។ ឯកសារទាំងនេះលើកឡើងអំពីបញ្ហាផ្ទៃក្នុងនៅជិតព្រំដែន ដោយសារតែការបង្កើតក្រុមតស៊ូខ្មែរ និងការគាំទ្រសម្ភារៈពីសំណាក់វៀតណាមក្នុង

---

[4] ទូរលេខការទូតសហរដ្ឋអាមេរិក ស្ថានទូតប្រចាំទីក្រុងបាងកក "ភាពងាយរងគ្រោះនៃរបបភ្នំពេញ" ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៧៨ BANGKO 23954 ឯកសារ **E383.1.3** កថាខណ្ឌ ១។

[5] ប្រតិចារឹកសវនាការ ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១ (សេចក្តីសន្និដ្ឋានបើកការចោទប្រកាន់) ឯកសារ **E1/13.1** ប្រហែលម៉ោង [14.59.12]។

[6] ទូរលេខការទូតអូស្ត្រាលី ស្ថានទូតប្រចាំទីក្រុងហាណូយ ចុះថ្ងៃទី ០៨ ខែ ឧសភា ឆ្នាំ ១៩៧៥ ឯកសារ **E383.1.1** កថាខណ្ឌ ៩។

[7] ទូរលេខការទូតអូស្ត្រាលី ស្ថានទូតប្រចាំទីក្រុងហាណូយ ចុះថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៧៥ ឯកសារ **E383.1.2** កថាខណ្ឌ ១១ កថាខណ្ឌ ១២ និងកថាខណ្ឌ ១៤។

[8] ទូរលេខការទូតសហរដ្ឋអាមេរិក ស្ថានទូតប្រចាំទីក្រុងបាងកក "ភាពងាយរងគ្រោះនៃរបបភ្នំពេញ" ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៧៨ BANGKO 23954 ឯកសារ **E383.1.3** កថាខណ្ឌ ៤ កថាខណ្ឌ ៧ និងកថាខណ្ឌ ៨។

[9] ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៩៩-២០៣។

ការបះបោររបស់ក្រុមទាំងនេះប្រឆាំងនឹងរបបខ្មែរក្រហម[10]។ យោងតាមព័ត៌មានដែលអាមេរិកទទួលបានតាមរយៈថៃ សោ ភឹម ទំនងជាបានដឹកនាំការវាយប្រយុទ្ធប្រឆាំងនឹង ប៉ុល ពត ហើយវៀតណាមបានចាត់ទុក សោ ភឹម ជាបុរសខ្លាំងនៃក្រុមតស៊ូ[11]។ ជាទូទៅ ទូរលេខទាំងនេះបង្ហាញអំពីអត្ថិភាពនៃក្រុមប្រដាប់អាវុធស្ទើរតែគ្រប់ទីកន្លែងលើទឹកដីនៃកម្ពុជាប្រជាធិបតេយ្យ ដែលក្នុងនោះ ក៏មានមេដឹកនាំជាន់ខ្ពស់មួយចំនួនចូលរួមផងដែរ។ បរិបទស្រពេចស្រពិលដែលបានរៀបរាប់នៅក្នុងទូរលេខទាំងនេះ ផ្តល់ការពន្យល់មួយដែលប្រឆាំងនឹងទស្សនៈដែលថាកម្ពុជាប្រជាធិបតេយ្យជារបបប្រមូលផ្តុំអំណាចតែនៅលើមនុស្សម្នាក់ និងជាប្រទីបបំភ្លឺធាតុផ្សំអង្គហេតុដែលចូលរួមចំណែកដល់ការបោសសម្អាត និងអស្ថិរភាពនៃរបបនោះ[12]។

៨. ម្យ៉ាងវិញទៀត ឯកសារទាំងនេះអាចនឹងត្រូវពិនិត្យរួមគ្នាជាមួយឯកសារផ្សេងទៀតដែលត្រូវបានអង្គជំនុំជម្រះទទួលយក ពាក់ព័ន្ធនឹងប្រធានបទដដែលនេះ។ វាជាការគួរឱ្យចាប់អារម្មណ៍ណាស់ក្នុងការវិភាគទូរលេខការទូតទាំងនេះជាមួយការសិក្សារបស់លោក Dmitry MOSYAKOV[13]។ ការសិក្សានេះត្រូវបានអង្គជំនុំជម្រះទទួលយកជាភស្តុតាង អនុលោមតាមវិធាន ៨៧(៤) នៅថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៥[14] ហើយផ្អែកជាចម្បងលើទូរលេខការទូតរវាងសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត និងសាធារណរដ្ឋសង្គមនិយមវៀតណាម និងផ្តល់នូវទស្សនៈរបស់សូវៀតទៅលើជម្លោះប្រដាប់។ នៅក្នុងបរិបទនៃសង្គ្រាមត្រជាក់ ការវិភាគរបស់អ្នកការទូតអាមេរិក និងអូស្ត្រាលី ទៅលើបញ្ហានេះ គឺជាភស្តុតាងបន្ថែមដ៏សំខាន់។

៩. អង្គជំនុំជម្រះបានចាត់ទុកការសិក្សារបស់លោក Dmitry MOSYAKOV ថាបានបំពេញលក្ខណៈ

---

[10] ទូរលេខការទូតសហរដ្ឋអាមេរិក ស្ថានទូតប្រចាំទីក្រុងបាងកក "ភាពងាយរងគ្រោះនៃរបបភ្នំពេញ" ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ១៩៧៨ BANGKO 23954 ឯកសារ **E383.1.3** កថាខណ្ឌ ៧។

[11] ដូចយោងខាងលើ។

[12] ទូរលេខការទូតសហរដ្ឋអាមេរិក ស្ថានទូតប្រចាំទីក្រុងបាងកក "កម្ពុជា - ការសន្ទនាជាមួយក្រុមតស៊ូ" ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៧៧ BANGKO 21997 ឯកសារ **E383.1.7** កថាខណ្ឌ ២ក កថាខណ្ឌ ៣ កថាខណ្ឌ ៧ និងកថាខណ្ឌ ១៦។

[13] "ខ្មែរក្រហម និងជនកុម្មុយនីស្តវៀតណាម៖ ប្រវត្តិនៃទំនាក់ទំនង ដូចមានរៀបរាប់នៅក្នុងបណ្ណសារសូវៀត" ឆ្នាំ ២០០៤ Dmitry MOSYAKOV ឯកសារ **E3/9644**។

[14] សេចក្តីសម្រេចលើសំណើរបស់ ខៀវ សំផន អនុលោមតាមវិធាន ៨៧(៤) សុំឱ្យទទួលយកឯកសារថ្មីៗដាក់ក្នុងសំណុំរឿង ០០២/០២ ឯកសារ **E347/1** កថាខណ្ឌ ៦។

វិនិច្ឆ័យនៃវិធាន ៨៧(៣) និងមានប្រយោជន៍ដល់ការស្វែងរកការពិត យោងតាមវិធាន ៨៧(៤)។ ទន្ទឹមនឹងនេះ អង្គជំនុំជម្រះត្រូវទទួលយកជាភ័ស្តុតាងនូវទូរលេខការទូតរបស់អូស្ត្រាលី និងអាមេរិក ដែលតាមដានយ៉ាងប្រកិតនូវការវិវត្តន៍នៃសភាពការណ៍នៅពេលនោះ។

១០. **<u>អាស្រ័យហេតុនេះ</u>** មេធាវីការពារក្តីស្នើសុំអង្គជំនុំជម្រះមេត្តា**ឯកភាព**តាមសំណើរបស់លោក នួន ជា សុំឱ្យទទួលយកជាភ័ស្តុតាងនូវទូរលេខការទូតទាំង ១១។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន<br><br>មេធាវី Anta GUISSÉ | រាជធានីភ្នំពេញ<br><br>រាជធានីភ្នំពេញ | |